ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជី ក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦




រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែតុលា ឆ្នាំ២០២៤

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

# មាតិកា


**បញ្ជីអក្សរកាត់** ........ I
**បញ្ជីតារាង** ........ II
**អារម្ភកថា** ........ III
**១. សេចក្តីផ្តើម** ........ ១
១.១. ស្ថានភាពបច្ចុប្បន្ន ........ ១
១.២. កត្តាប្រឈមនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ........ ៣
១.៣. ការលើកទឹកចិត្តសហគ្រាស គ្រឹះស្ថាន ........ ៥
១.៤. ភាពចាំបាច់ក្នុងការរៀបចំផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ........ ៦
**២. គោលបំណង និងគោលដៅ** ........ ៦
**៣. វិសាលភាព** ........ ៧
**៤. វិធានការគន្លឹះ** ........ ៧
៤.១. ការសម្រួលយន្តការ និងនីតិវិធីនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ........ ៧
៤.២. ការផ្តល់ការលើកទឹកចិត្ត ........ ៨
៤.៣. ការជំរុញការអនុលោមតាមបទប្បញ្ញត្តិ ........ ៩
៤.៤. ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន ........ ១០
**៥. ក្របខណ្ឌពេល និងស្ថាប័នសម្របសម្រួល និងអនុវត្ត** ........ ១១
**៦. យន្តការតាមដាន និងវាយតម្លៃ** ........ ១២
**៧. សេចក្តីសន្និដ្ឋាន** ........ ១៣
**ឧបសម្ព័ន្ធ ១ ៖ តារាងផែនការសកម្មភាព** ........ ១៤
**ឧបសម្ព័ន្ធ ២ ៖ និយមន័យ** ........ ១៧

# បញ្ជីអក្សរកាត់

| | |
|---|---|
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ក.ក.ប. | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ព.ណ. | ក្រសួងពាណិជ្ជកម្ម |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| គ.ស.អ.ស.ក. | គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| គ.ស.ហ. | គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អ.ព.ដ. | អគ្គនាយកដ្ឋានពន្ធដារ នៃ ក.ស.ហ.វ. |
| អ.ក.គ. | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange) |
| GIZ | ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (The Deutsche Gesellschaft für Internationale Zusammenarbeit) |
| ILO | អង្គការអន្តរជាតិខាងការងារ (International Labour Organization) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme) |

# បញ្ជីតារាង

តារាងទី១៖ ប្រជាជនមានការងារធ្វើតាមស្ថានភាពការងារឆ្នាំ២០១៩ .................................... ១
តារាងទី២៖ ចំនួនអង្គភាពសេដ្ឋកិច្ច និងចំនួនអ្នកធ្វើការ/ កម្មករនិយោជិត .............................. ២

# អារម្ភកថា

សុខសន្តិភាព និងស្ថិរភាពនយោបាយ ជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដែលធ្វើឱ្យកម្ពុជាមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិយ៉ាងឆាប់រហ័ស ជាមួយនឹងសមិទ្ធផលនានាគួរជាទីមោទនៈ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អគ្គមគ្គុទេសក៍ឯកនៃកម្ពុជា និងក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមគ្គុទេសក៍វ័យក្មេងដ៏ឆ្នើម និងពោរពេញដោយសមត្ថភាព, ចំណេះដឹង និងថាមពល។

ជាមួយនឹងមនុញ្ញផលនៃការអភិវឌ្ឍឥតឈប់ឈរនេះ ស្របតាមនិន្នាការតំបន់ និងសកល រួមទាំងស្ថានការណ៍ប្រចក្សនៅកម្ពុជា, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ត្រូវបានរាជរដ្ឋាភិបាលអនុម័ត និងដាក់ឱ្យប្រើប្រាស់ ដោយមានក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលបន្ទុកក្នុងការធ្វើនិម្មាបនកម្មប្រព័ន្ធគាំពារសង្គម និងដាក់ចេញនូវគោលនយោបាយគាំពារសង្គមពាក់ព័ន្ធជាបន្តបន្ទាប់ ក្នុងគោលបំណងធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំដៅទប់ស្កាត់ពលរដ្ឋកម្ពុជាកុំឱ្យធ្លាក់ចូលក្នុងរណ្តៅនៃភាពក្រីក្រ ដោយឈរលើអភិក្រម "**មិនបោះបង់ពលរដ្ឋណាម្នាក់**"។

ទន្ទឹមនេះ, អភិបាលកិច្ចប្រព័ន្ធគាំពារសង្គមក៏ត្រូវបានរៀបចំឡើង សម្រាប់ជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានប្រសិទ្ធភាព ភាពរឹងមាំ និងជវភាព ដែលរួមចំណែកជាកាតាលីករគាំទ្រដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ជាវឌ្ឍនភាព, ការវិនិយោគលើប្រព័ន្ធគាំពារសង្គមបានកើនឡើងពីប្រមាណ ១% នៃ **ផ.ស.ស.** ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ៣,១% ក្នុងឆ្នាំ ២០២២ ជាមួយនឹងអត្រាគ្របដណ្តប់កើនឡើងពី ២៦,៥% ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ៤៤% ឬស្មើនឹង ៧,៥ លាននាក់ នៃចំនួនប្រជាជនកម្ពុជាសរុប ក្នុងឆ្នាំ២០២៤។ យ៉ាងណាក៏ដោយ, ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមមិនបញ្ឈប់ត្រឹមនេះទេ ផ្ទុយទៅវិញ វិសាលភាពនៃការគ្របដណ្តប់ដោយប្រព័ន្ធគាំពារសង្គមកំពុងត្រូវបានបន្តពង្រីកជាបន្តបន្ទាប់ និងជំហានៗ ដូចមានកំណត់ក្នុងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងក៏មានកំណត់ផងដែរក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ តាមលទ្ធភាពដែលអាចទ្រទ្រង់បានដោយថវិកាជាតិ។

បន្ថែមលើអន្តរាគមន៍គាំពារសង្គមជាបន្តបន្ទាប់ ជាពិសេស ក្នុងអំឡុងនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញ "**ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១-២០២៣**" ដែលជាផែនទីបង្ហាញផ្លូវសម្រាប់រៀបចំគោលនយោបាយពាក់ព័ន្ធ ដើម្បីស្តារកំណើនសេដ្ឋកិច្ចក្នុងពេលចំពោះមុខ និងរយៈពេលមធ្យម ឱ្យត្រលប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន។ ជាមួយគ្នានេះ, "**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**" ត្រូវបានដាក់ឱ្យអនុវត្ត កាលពីឆ្នាំ២០២៣ ក្នុងគោលបំណងលើកកម្ពស់ការគាំពារ និងការពង្រឹងសមត្ថភាព ផលិតភាព និងភាពធន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងជំរុញ និងពន្លឿនការចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីចូលរួមគាំទ្រទាំងដោយផ្ទាល់ និងដោយប្រយោលដល់សេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធ ជាពិសេសការរៀបចំ និង

ដាក់ឱ្យអនុវត្តវិធានការ ឬកម្មវិធីលើកទឹកចិត្តឱ្យក្រុមហ៊ុន សហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ចុះបញ្ជីបុគ្គលិកទាំងអស់ក្នុងប្រព័ន្ធបេឡាជាតិសន្តិសុខសង្គម។

ដើម្បីចូលរួមសម្រេចបាននូវយុទ្ធសាស្ត្រខាងលើនេះ, **ក្រុមប្រឹក្សាជាតិគាំពារសង្គម** បានរៀបចំ និងដាក់ឱ្យអនុវត្ត "**ផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦**" ដែលជាឧបករណ៍គោលនយោបាយផ្សារភ្ជាប់នឹងគោលបំណង និងការងារអាទិភាព ដូចមានកំណត់ក្នុងក្របខណ្ឌយុទ្ធសាស្ត្រខាងលើ ក្នុងគោលបំណងពង្រីកការគ្របដណ្តប់កិច្ចគាំពារផ្នែកសន្តិសុខសង្គមទៅដល់កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រកបដោយសមធម៌ និងបរិយាបន្ន សំដៅលើកកម្ពស់សុខុមាលភាពរបស់ពួកគេ តាមរយៈការដាក់ចេញនូវវិធានការគន្លឹះចំនួន ៤ គឺៈ (១) ការសម្រួលយន្តការ និងនីតិវិធីនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម, (២) ការផ្តល់ការលើកទឹកចិត្ត, (៣) ការជំរុញអនុលោមភាពតាមបទប្បញ្ញត្តិ និង (៤) ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន។

ផែនការប្រតិបត្តិនេះ ត្រូវបានសម្របសម្រួលរៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង-ស្ថាប័ន និងតួអង្គពាក់ព័ន្ធ រួមមានអង្គការជាតិ និងអន្តរជាតិ ព្រមទាំងសមាគមនានា ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយទាំងទិដ្ឋភាពបច្ចេកទេស និងនយោបាយ ដែលធ្វើឱ្យផែនការនេះអាចអនុវត្តបាន និងមានសង្គតិភាពជាមួយឯកសារគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមថ្លែងអំណរគុណក្រុមការងារ និងថ្នាក់ដឹកនាំនៃបណ្តាក្រសួង-ស្ថាប័ន, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម, ដៃគូអភិវឌ្ឍន៍ ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP), និងភាគីពាក់ព័ន្ធដែលបានផ្តល់ធាតុចូល និងកិច្ចសហការខ្ពស់ ក្នុងការរៀបចំផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦ ឱ្យលេចចេញជារូបរាងឡើង។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រប់តួអង្គពាក់ព័ន្ធនឹងបន្តផ្តល់កិច្ចសហការ និងចូលរួមជាសហថាមពលអនុវត្តផែនការប្រតិបត្តិនេះ ឱ្យកាន់តែរលូន និងមានប្រសិទ្ធភាព ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា។

ថ្ងៃ ពុធ ១៣រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា គ.ស. ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

SOCIAL PROTECTION CAMBODIA
NATIONAL SOCIAL PROTECTION COUNCIL

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ១. សេចក្តីផ្តើម

## ១.១. ស្ថានភាពបច្ចុប្បន្ន

សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រកម្រិតជីវភាពរបស់ប្រជាជន ជាពិសេសដល់អ្នកប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានផលិតភាពទាប និងចំណូលមិនស្ថិតស្ថេរ និងងាយទទួលរងហានិភ័យនៅពេលមានវិបត្តិផ្សេងៗ តួយ៉ាង ការរាតត្បាតនៃជំងឺកូវីដ-១៩ សម្ពាធអតិផរណា និងគ្រោះធម្មជាតិ ជាដើម។ ទោះយ៉ាងណា, សេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំ និងមានលក្ខណៈពហុវិស័យ ដែលបង្កឱ្យមានភាពស្មុគស្មាញដល់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងកំណត់អត្តសញ្ញាណ ដើម្បីផ្តល់ការគាំទ្រ និងកិច្ចគាំពារនានា សំដៅលើកកម្ពស់កម្រិតជីវភាពព្រមទាំងការចូលរួមរបស់ប្រជាជនទៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ផ្អែកតាមអង្កេតកម្លាំងពលកម្មឆ្នាំ២០១៩, កម្ពុជាមានអ្នកធ្វើការងារក្រៅប្រព័ន្ធប្រមាណ ៨៨% (ប្រុស ៨៩% និងស្រី៨៧,៦%) ដែលមិនទទួលបានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកពេលព្យាបាលជំងឺ និងមិនទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម ទោះបីជាបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនានា មានវិសាលភាពគ្របដណ្តប់ដល់ក្រុមគោលដៅទាំងនោះក៏ដោយ។ ប្រភពទិន្នន័យដដែលនេះ បានបង្ហាញផងដែរថា ក្នុងឆ្នាំ២០១៩ ប្រជាជនមានការងារធ្វើនៅកម្ពុជា មានចំនួនជិត ៧,៩ លាននាក់ ដែលក្នុងនោះភាគច្រើន ជាកម្មករនិយោជិត ដែលមានចំនួន ៣,៨ លាននាក់ (៤៧,៨%) ដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថាន និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនមានចំនួន ២,៩ លាននាក់ (៣៦,៩ %)។ ដោយឡែក ចំនួននិយោជក និងអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល នៅមានទំហំតូចបើធៀបនឹងចំនួនប្រជាជនសរុបដែលមានការងារធ្វើនៅក្នុងឆ្នាំ២០១៩។

### តារាងទី១៖ ប្រជាជនមានការងារធ្វើតាមស្ថានភាពការងារឆ្នាំ២០១៩

| ក្រុមប្រជាជន | ចំនួន | ភាគរយ |
|---|---|---|
| កម្មករនិយោជិត | ៣ ៧៦៩ ៥១៥ | ៤៧,៨ |
| និយោជក | ២៦៩ ៨២០ | ៣,៤ |
| អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ២ ៩០៨ ៤៤៧ | ៣៦,៩ |
| អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល | ៩៣៥ ៣២៤ | ១១,៩ |
| **សរុប/មធ្យម** | **៧ ៨៨៣ ១០៦** | **១០០** |

*ប្រភព៖ អង្កេតកម្លាំងពលកម្មឆ្នាំ ២០១៩*

ជាមួយគ្នានេះ របាយការណ៍ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ បានបង្ហាញថា ប្រទេសកម្ពុជាមានអង្គភាពសេដ្ឋកិច្ចសរុបចំនួន **៧៥៣ ៦៧០** (មានអ្នកធ្វើការចំនួន **២ ៩៨០ ៥៦៩ នាក់**) ដែលក្នុងនោះមានសហគ្រាស គ្រឹះស្ថានចំនួន **៩៣ ៦៤៧** (មានអ្នកធ្វើការចំនួន **១ ៨៩៤ ០៥៥ នាក់**)

បានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលចំនួននេះមិនបានរាប់បញ្ចូលវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, សកម្មភាពគ្រួសារ, វិស័យការទូត, ផ្នែករាជរដ្ឋាភិបាល, ផ្នែកយោធា, និងអាជីវកម្មចល័តដែលមិនមានទីតាំងជាក់លាក់។ ទោះយ៉ាងណា, ទិន្នន័យប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) បានបង្ហាញថា ប្រមាណតែ ២៣% នៃសហគ្រាសគ្រឹះស្ថាន ដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធខាងលើ កំពុងដំណើរការក្នុងប្រព័ន្ធ **ប.ស.ស.** ខណៈពេលដែលសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជាច្រើនទៀតមិនទាន់បានចុះបញ្ជីជាមួយ **ប.ស.ស.**។ ដូច្នេះ **ប.ស.ស.** ត្រូវបន្តពង្រឹងយន្តការជំរុញសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលបានចុះបញ្ជីរួចរាល់ ឱ្យមកចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គមផងដែរដើម្បីទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមរបស់រាជរដ្ឋាភិបាល។

បន្ថែមលើនេះ, ផ្អែកតាមទិន្នន័យប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់ **ប.ស.ស.** និងអង្កេតកម្លាំងពលកម្ម ឆ្នាំ២០១៩ ខាងលើ, និយោជក និងកម្មករនិយោជិត មានចំនួនសរុបប្រមាណជាង ៤ លាននាក់ ដែលបម្រើការងារនៅក្នុងអង្គភាពសេដ្ឋកិច្ចដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាត ដែលក្នុងនោះ មានប្រមាណជាង ២ លាននាក់ ពុំទាន់បានចុះឈ្មោះក្នុងប្រព័ន្ធ **ប.ស.ស.**។ ដោយឡែក គិតត្រឹមរយៈពេលដូចគ្នា, បុគ្គលស្វ័យនិយោជន៍ ចំនួន ២៣៨ ៦៨៨ នាក់ ឬស្មើនឹង ៨ % ក្លាយជាសមាជិកសកម្មក្នុងប្រព័ន្ធ **ប.ស.ស.** បើធៀបនឹងចំនួនបុគ្គលស្វ័យនិយោជន៍សរុបចំនួន ២ ៩០៨ ៤៤៧ នាក់។ ទោះយ៉ាងណា, បុគ្គលស្វ័យនិយោជន៍មួយចំនួនតូច ដែលមានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ កំពុងទទួលបានអត្ថប្រយោជន៍ក្រោមកម្មវិធីជាតិជំនួយសង្គមនានា និងមូលនិធិសមធម៌សុខាភិបាល។

### តារាងទី២៖ ចំនួនអង្គភាពសេដ្ឋកិច្ច និងចំនួនអ្នកធ្វើការ/ កម្មករនិយោជិត

| | ជំរឿនសេដ្ឋកិច្ច ២០២២ | | | | | ចុះបញ្ជី ប.ស.ស. ២០២៤ | |
|---|---|---|---|---|---|---|---|
| | ចំនួនសរុប | បានចុះបញ្ជី | | មិនបានចុះបញ្ជី | | | |
| | | ចំនួន (១) | % | ចំនួន | % | ចំនួន (២) | % (២/១) |
| **អង្គភាពសេដ្ឋកិច្ច** | ៧៥៣ ៦៧០ | ៩៣ ៦៤៧ | **១២,៤** | ៦៦០ ០២៣ | **៨៧,៦** | ២១ ៨៨៤ | **២៣** |
| **អ្នកធ្វើការ/ កម្មករនិយោជិត** | ២ ៩៨០ ៥៦៩ | ១ ៨៩៤ ០៥៥ | **៦៣,៥** | ១ ០៨៦ ៥១៤ | **៣៦,៥** | ១ ៥៧០ ៧៩៩ | |

*ប្រភព៖ ជំរឿនសេដ្ឋកិច្ច២០២២, បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ២០២៤*

ផ្អែកលើស្ថានភាពនេះ, "ផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ ២០២៤-២០២៦" ត្រូវបានរៀបចំដើម្បីចូលរួមជំរុញការពង្រីកវិសាលភាពនៃកិច្ចគាំពារផ្នែក

សន្តិសុខសង្គមប្រកបដោយសមធម៌ និងបរិយាបន្ន ដែលឆ្លើយតបនឹងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលក្នុងនោះរួមមាន ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥, យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨, និងផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥។

## ១.២. កត្តាប្រឈមនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

ផ្អែកតាមលទ្ធផលនៃការសិក្សា និងកិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធ រួមមានតំណាងសមាគម អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន, ការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គមជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗមួយចំនួន ដូចខាងក្រោម៖

### ក. នីតិវិធីចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

ដើម្បីចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.**, តំណាងសហគ្រាស គ្រឹះស្ថាន ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដោយភ្ជាប់មកជាមួយនូវសំណុំឯកសារ ដូចជាទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន, បញ្ជិកាពាណិជ្ជកម្ម, បណ្ណប៉ាតង់, របាយការណ៍ប្រើប្រាស់កម្មករនិយោជិត, និងអត្តសញ្ញាណប័ណ្ណ/ ឬលិខិតឆ្លងដែន និងសៀវភៅគ្រួសារ/ ឬសៀវភៅស្នាក់នៅ ជាដើម។ កម្មករនិយោជិតត្រូវចំណាយពេលធ្វើដំណើរទៅចុះឈ្មោះដោយតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារសម្គាល់ខ្លួន និងលិខិតបញ្ជាក់ការងារ។ លទ្ធផលនៃកិច្ចពិភាក្សាជាមួយតំណាងសហគ្រាស គ្រឹះស្ថាន និងក្រុមគោលដៅនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គមដែលសហការរៀបចំដោយអង្គការ ILO និង UNDP នៅឆ្នាំ២០២៣ បានបង្ហាញថា កម្មករនិយោជិតភាគច្រើនសុំច្បាប់ឈប់សម្រាកយ៉ាងតិចកន្លះថ្ងៃពីកន្លែងការងារសម្រាប់ការទៅចុះឈ្មោះដែលតម្រូវឱ្យផ្តិតមេដៃ ខណៈពេលពួកគាត់មានភាពមមាញឹកក្នុងការបំពេញការងារ។

### ខ. ការយល់ដឹង និងការផ្សព្វផ្សាយអំពីរបបសន្តិសុខសង្គម

លទ្ធផលនៃការសិក្សាមួយចំនួនបានបង្ហាញថា សាធារណជន ជាពិសេសនិយោជក និងកម្មករនិយោជិត គួរតែត្រូវទទួលបានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមដែលកំពុងអនុវត្ត និងសិទ្ធិទទួលបានការគាំពារ និងអំពីនីតិវិធីនិងកាតព្វកិច្ចចុះឈ្មោះ ជាដើម ខណៈដែលការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម នៅមានកម្រិតទាប។ យ៉ាងណាមិញ, របាយការណ៍ស្រាវជ្រាវឆ្នាំ២០២៤ របស់ **ប.ស.ស.** ដែលមានកិច្ចសហការពី GIZ បានបង្ហាញថា ៩៧% នៃសមាជិក **ប.ស.ស.** ពេញចិត្តលើការទទួលបានអត្ថប្រយោជន៍ផ្នែកថែទាំសុខភាព, ៩៣% ពេញចិត្តលើការផ្តល់សេវា **ប.ស.ស.** និងមូលដ្ឋានសុខាភិបាល, និង ៨៧% មានការយល់ដឹងពីការអនុវត្តរបបសន្តិសុខសង្គម។

## គ. ក្របខណ្ឌគតិយុត្ត

ច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ មានវិសាលភាពអនុវត្តចំពោះ៖ (១) បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ, (២) បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើតាមផ្ទះ និង (៣) បុគ្គលស្វ័យនិយោជន៍។ ម្យ៉ាងទៀត យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ បានកំណត់វិសាលភាព និងការធ្វើអាទិភាវូបនីយកម្មវិស័យ និងប្រភេទអាជីវកម្មមុខរបរ និងការងារអាទិភាព សម្រាប់ជំរុញឱ្យចូលក្នុងប្រព័ន្ធ និងទទួលបានការគាំពារជាជំហានៗ។ ទោះយ៉ាងណា ក្នុងចំណោមក្រុមគោលដៅអាទិភាពទាំង ១៥ ដែលបានកំណត់ ពុំទាន់ត្រូវបានកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ និងបែងចែកច្បាស់លាស់អំពីប្រភេទ ឬមុខសញ្ញាដែលត្រូវគិតគូរផ្តល់អត្ថប្រយោជន៍គាំពារសង្គមមុនគេ និងពុំទាន់មានផែនការជាក់លាក់ក្នុងការជំរុញឱ្យចុះឈ្មោះ និងទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម។

## ឃ. ការជំរុញការអនុលោមតាមបទប្បញ្ញត្តិ

ការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកង្វះយន្តការពង្រឹងការអនុវត្តច្បាប់ទាមទារឱ្យមានភាពចាំបាច់ក្នុងការបង្កើតយន្តការពង្រឹងការអនុវត្តច្បាប់ និងការបង្កើនកិច្ចសហការពីភាគីពាក់ព័ន្ធ ដើម្បីឱ្យអធិការការងារ និងអធិការសន្តិសុខសង្គមមានភាពងាយស្រួលក្នុងការចុះត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយពីអនុលោមភាពនៃបទប្បញ្ញត្តិចំពោះសហគ្រាស គ្រឹះស្ថានមួយចំនួននៅតាមមូលដ្ឋាន។ ការបង្កើតយន្តការពង្រឹងការអនុវត្តច្បាប់នាពេលខាងមុខនឹងអាចធ្វើឱ្យការកំណត់អត្តសញ្ញាណក្រុមគោលដៅមានភាពពេញលេញ និងការអនុវត្តវិធានការមានភាពតឹងរ៉ឹងជាងនេះ។ លើសពីនេះ អនុលោមតាមមាត្រា៩៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម បានចែងថា "និយោជកនៃសហគ្រាស គ្រឹះស្ថានដែលមិនអនុវត្តកាតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់ ឬមិនអនុវត្តកាតព្វកិច្ចរាយការណ៍ពីកម្មករនិយោជិតឱ្យបានត្រឹមត្រូវ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍" ដែលជាក់ស្តែង **ប.ស.ស.** ត្រូវបន្តអនុវត្តកិច្ចការនេះឱ្យបានពេញលេញជាងនេះ។

## ង. ការចែករំលែកទិន្នន័យ

ទិន្នន័យសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (OBR) និងចុះបញ្ជីនៅតាមក្រសួង-ស្ថាប័នមួយចំនួន ត្រូវបានចែករំលែកតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលជាថ្នាលឌីជីថលគ្រឹះសម្រាប់ផ្លាស់ប្តូរទិន្នន័យ តាមរយៈការធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័ររវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជនដែលជាសមាជិករបស់ថ្នាល CamDX។ បច្ចុប្បន្ន មានតែទិន្នន័យក្រុមហ៊ុន សហគ្រាសធុនតូច និងមធ្យម និងធុនធំប៉ុណ្ណោះ ដែលត្រូវបានចែករំលែកតាមថ្នាលនេះ បន្ទាប់ពីបានចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានជាមួយក្រសួង-

ស្ថាប័នពាក់ព័ន្ធ រួមមាន៖ ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាដើម។ ដោយឡែក ការចុះបញ្ជីអាជីវកម្មសម្រាប់សហគ្រាសធុនមីក្រូ ត្រូវបានដាក់ឱ្យអនុវត្តនៅអង្គភាពច្រកចេញ-ចូលតែមួយនៃរដ្ឋបាលក្រុង/ស្រុក-ខណ្ឌទូទាំងរាជធានី-ខេត្ត ប៉ុន្តែពុំទាន់មានយន្តការចែករំលែកទិន្នន័យទៅរដ្ឋបាលថ្នាក់ជាតិនៅឡើយ។ ម្យ៉ាងទៀត ទោះបីជាប្រព័ន្ធ OBR និងថ្នាល CamDX ត្រូវបានដាក់ឱ្យដំណើរការ, ការចែករំលែកទិន្នន័យពាក់ព័ន្ធនឹងប្រភេទ និងចំនួនសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជី ក៏ពុំទាន់បានទូលំទូលាយនោះទេ ដោយហេតុថា៖ (១) ថ្នាលនេះបានចែករំលែកទិន្នន័យការចុះបញ្ជីអាជីវកម្ម ចាប់ពីពាក់កណ្តាលឆ្នាំ២០២០ តែប៉ុណ្ណោះ, (២) ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន រួមទាំង **ប.ស.ស.** ផងដែរ ពុំទាន់បានចែករំលែកទិន្នន័យពេញលេញនៅក្នុងថ្នាល CamDX (ឧទាហរណ៍៖ ទិន្នន័យរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ឬផ្នែករបបសោធន) និង (៣) ទិន្នន័យរបស់សហគ្រាស គ្រឹះស្ថានដែលបានចែករំលែកតាមថ្នាល CamDX មួយចំនួនពុំទាន់បានធ្វើបច្ចុប្បន្នកម្ម ដោយហេតុថា មុខងារធ្វើបច្ចុប្បន្នកម្មអាសយដ្ឋានទើបតែត្រូវបានដាក់ឱ្យអនុវត្តនៅលើប្រព័ន្ធ OBR នៅដើមឆ្នាំ២០២៤ នេះប៉ុណ្ណោះ។ ការចែករំលែកទិន្នន័យមិនបានពេញលេញក៏ជាកត្តារាំងស្ទះដល់ការជំរុញការអនុលោមតាមបទប្បញ្ញត្តិឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពផងដែរ។

### ១.៣. ការលើកទឹកចិត្តសហគ្រាស គ្រឹះស្ថាន

ដើម្បីលើកកម្ពស់ការអភិវឌ្ឍសហគ្រាស គ្រឹះស្ថាន និងការចុះបញ្ជីក្នុងប្រព័ន្ធ, រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តសំខាន់ៗដល់សហគ្រាស គ្រឹះស្ថាន ជាពិសេសការលើកទឹកចិត្តក្នុងការបង់ភាគទាន **ប.ស.ស.**, ការលើកទឹកចិត្តផ្នែកពន្ធដារ, និងការផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាបពីធនាគារសហគ្រាសធុនតូច និងមធ្យម (SME) ក្នុងលក្ខខណ្ឌសមស្រប។ ជាក់ស្តែង រាជរដ្ឋាភិបាល បានផ្អាកការបង់ភាគទាន **ប.ស.ស.** សម្រាប់កម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារនៅសហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩។ បន្ថែមលើនេះ, **ប.ស.ស.** ក៏បានអនុវត្តការលើកលែងការផាកពិន័យចំពោះសហគ្រាស គ្រឹះស្ថានមួយចំនួនដែលមិនបានរាយការណ៍ចំនួនកម្មករនិយោជិត និងបង់ភាគទានឱ្យបានទាន់ពេលក្រោមហេតុផលសត្យានុម័តដែលអាចទទួលយកបាន។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាល បានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ដោយបានផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូលចាប់ពី ៣ ទៅ ៥ឆ្នាំ ដល់សហគ្រាសធុនតូច និងមធ្យម, លុបចោលនូវពន្ធលើរបបម៉ៅការសម្រាប់សហគ្រាសធុនមីក្រូ និងពន្ធប្រថាប់ត្រាលើលិខិតស្តីពីការបង្កើតសហគ្រាស និងកាត់បន្ថយពន្ធប៉ាតង់ ៥០% សម្រាប់ឆ្នាំដំបូងនៃការចុះបញ្ជីអាជីវកម្ម។ ដើម្បីចូលរួមគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, រាជរដ្ឋាភិបាល ក៏បានផ្តល់

ការលើកទឹកចិត្តផ្នែកពន្ធដារមួយចំនួនបន្ថែមទៀតដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម។ ម្យ៉ាងទៀត ក្រោមគម្រោងសហហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល, ធនាគារ SME បានផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យមដែលទើបបង្កើតថ្មីក្នុងអត្រាការប្រាក់អតិបរមា ៧% ក្នុងមួយឆ្នាំ សម្រាប់កម្ចីរយៈពេលអតិបរមា ៧ឆ្នាំ។ លើសពីនេះ រាជរដ្ឋាភិបាល ក៏បានរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលដៅសម្រួល និងលើកទឹកចិត្តដល់ការចុះបញ្ជីអាជីវកម្មផងដែរ។

ទោះយ៉ាងណា រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការគិតគូបន្ថែម និងរៀបចំយន្តការ ឬកម្មវិធីលើកទឹកចិត្តជាក់លាក់ណាមួយសម្រាប់ទាក់ទាញឱ្យសហគ្រាស គ្រឹះស្ថាន មកចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម។

### ១.៤. ភាពចាំបាច់ក្នុងការរៀបចំផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

ដើម្បីផ្សារភ្ជាប់នឹងគោលបំណងនៃក្របខណ្ឌយុទ្ធសាស្ត្រ និងចូលរួមដោះស្រាយកត្តាប្រឈមខាងលើ, ការរៀបចំផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦ ពិតជាចាំបាច់ដើម្បីផ្តល់ការគាំទ្រ និងជំរុញសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចុះឈ្មោះក្នុងប្រព័ន្ធ **ប.ស.ស.** សំដៅលើកកម្ពស់សុខុមាលភាពរបស់ពួកគេតាមរយៈវិធានការគន្លឹះចំនួន ៤ ដូចខាងក្រោម៖

- ការសម្រួលយន្តការ និងនីតិវិធីនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម
- ការផ្តល់ការលើកទឹកចិត្ត
- ការជំរុញការអនុលោមតាមបទប្បញ្ញត្តិ
- ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន។

## ២. គោលបំណង និងគោលដៅ

ផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦ មានគោលបំណងចូលរួមពង្រីកការគ្របដណ្តប់កិច្ចគាំពារផ្នែកសន្តិសុខសង្គមទៅដល់កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងខាងលើ, ផែនការនេះកំណត់គោលដៅចម្បងៗ ដូចខាងក្រោម៖

- ជំរុញការចូលរួមរបស់តំណាងសហគ្រាស គ្រឹះស្ថាន និងភាគីពាក់ព័ន្ធ ដែលក្នុងនោះមានសមាគមអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងដំណើរការពាក់ព័ន្ធនឹងការជំរុញការចុះបញ្ជីនិយោជក និងកម្មករនិយោជិតក្នុងប្រព័ន្ធសន្តិសុខសង្គម
- បង្កើនចំនួនសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចុះឈ្មោះក្នុងប្រព័ន្ធ **ប.ស.ស.** ដោយប្រើប្រាស់នីតិវិធីសាមញ្ញ បត់បែន និងមានប្រសិទ្ធភាព តាមរយៈវិធានការគន្លឹះដែលបានដាក់ចេញ។

**ប.ស.ស.** នឹងកើនសមាជិកថ្មី យ៉ាងហោចណាស់ ១,២ លាននាក់ តាមរយៈការអនុវត្តផែនការប្រតិបត្តិនេះ រយៈពេល ២ឆ្នាំ ចាប់ពី ឆ្នាំ២០២៤ ដល់ ២០២៦។

## ៣. វិសាលភាព

ផែនការប្រតិបត្តិនេះ មានវិសាលភាពចំពោះក្រុមគោលដៅចំនួន ៣ ប្រភេទសំខាន់ៗ គឺ៖

១. កម្មករនិយោជិតដែលកំពុងបម្រើការងារនៅក្នុងអង្គភាពសេដ្ឋកិច្ច ដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាត និងមានវិញ្ញាបនបត្របញ្ជិកា **ប.ស.ស.** ប៉ុន្តែពួកគេមិនត្រូវបានរាយការណ៍ និងចុះឈ្មោះក្នុងប្រព័ន្ធ **ប.ស.ស.**។

២. អង្គភាពសេដ្ឋកិច្ច ដែលក្នុងនោះមានសហគ្រាសធុនតូច និងមធ្យម ដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាត ប៉ុន្តែពុំទាន់បានចុះបញ្ជីនៅក្នុងប្រព័ន្ធ **ប.ស.ស.**។

៣. អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលក្នុងនោះមានសហគ្រាសធុនមីក្រូ កម្មករនិយោជិតនៃសហគ្រាសធុនមីក្រូ កម្មករនិយោជិតម្ដងម្កាល និងបុគ្គលស្វ័យនិយោជន៍ ដែលបានចុះឈ្មោះក្នុងថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ៤. វិធានការគន្លឹះ

ដើម្បីសម្រេចតាមគោលបំណងនិងគោលដៅខាងលើ, ផែនការប្រតិបត្តិនេះ កំណត់នូវវិធានការគន្លឹះ ចំនួន ៤ ដែលមានភាពប្រទាក់ក្រឡា និងបំពេញគ្នា ដូចខាងក្រោម៖

### ៤.១. ការសម្រួលយន្តការ និងនីតិវិធីនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម

វិធានការនេះ មានគោលបំណងសម្រួលនីតិវិធី និងដំណើរការចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.** ដោយកាត់បន្ថយឯកសារតម្រូវ និងនីតិវិធីមិនចាំបាច់នានាឱ្យនៅកម្រិតអប្បបរមា ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការជំរុញការចុះបញ្ជី។ ការបង្កភាពងាយស្រួល គួបផ្សំនឹងការកាត់បន្ថយបន្ទុកចំណាយថវិកា និងពេល សម្រាប់ការចុះបញ្ជី ពិតជាចាំបាច់ក្នុងការទាក់ទាញនិយោជក កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.**។

ដើម្បីសម្រេចបានការងារនេះដោយជោគជ័យ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវសិក្សា និងគិតគូរលើចំណុចមួយចំនួន ដូចខាងក្រោម៖

- កែលម្អប្រព័ន្ធចុះបញ្ជីអនឡាញដែលមានស្រាប់ឱ្យកាន់តែរលូន និងកាត់បន្ថយឯកសារតម្រូវ និងនីតិវិធីមិនចាំបាច់ (ឧទាហរណ៍៖ មិនតម្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការងារ)។

- ជំរុញឱ្យកម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.** តាមរយៈទូរសព្ទវៃឆ្លាត (Mobile App) ឬកម្មវិធីគេហទំព័រ (Web App) ដែលមានស្រាប់ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬបណ្ណឪជីថល និងលិខិតបញ្ជាក់ពីតំណាងសហគ្រាស គ្រឹះស្ថាន ដើម្បីបញ្ជាក់អត្តសញ្ញាណកម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ បច្ចុប្បន្ន **ប.ស.ស.** បានសម្រួលនីតិវិធីជាបណ្ដើរៗក្នុងការចុះបញ្ជីតាមរយៈ Mobile App, Web App និងបង្កើនទីតាំងនៅតាមទីប្រជុំជន ខេត្ត ក្រុង ស្រុក ខណ្ឌ និងតាមផ្សារទំនើប ព្រមទាំងបម្រើសេវាកម្មពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ពីម៉ោង ៨:៣០ នាទី ដល់ម៉ោង ១៧:៣០នាទី (លើកលែង ស្នាក់ការកណ្ដាលពីម៉ោង ៧:០០នាទី ដល់ម៉ោង ២២:០០នាទី) និងផ្ដល់សេវាអតិថិជន (Hotline) ២៤/៧ តាមរយៈលេខ ១២៨៦ និង១២៩៧។
- ពិនិត្យលទ្ធភាពរៀបចំយន្តការ ឬប្រព័ន្ធចែករំលែកទិន្នន័យនៃចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ មុនវត្តមានថ្នាល CamDX ដាក់ឱ្យដំណើរការតាមរយៈការកត់ត្រាការចុះបញ្ជីឡើងវិញក្នុងប្រព័ន្ធនេះ។
- ពិនិត្យលទ្ធភាពរៀបចំយន្តការចែករំលែកទិន្នន័យអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបានចុះឈ្មោះក្នុងថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ មកប្រព័ន្ធ **ប.ស.ស.** ដើម្បីជាមូលដ្ឋានសម្រាប់គិតគូរ និងវាយតម្លៃលទ្ធភាពចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម។

### ៤.២. ការផ្ដល់ការលើកទឹកចិត្ត

វិធានការនេះ មានគោលបំណងលើកទឹកចិត្ត និងទាក់ទាញម្ចាស់សហគ្រាស គ្រឹះស្ថាន, កម្មករនិយោជិត, និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.**។ ក្នុងទិដ្ឋភាពសាកល, ក្រៅពីទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម, សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម អាចត្រូវបានផ្ដល់ការលើកទឹកចិត្តតាមរូបភាពផ្សេងៗ ដូចជា លទ្ធភាពចូលក្នុងលទ្ធកម្មសាធារណៈ, ការទទួលបានសេវាហិរញ្ញវត្ថុ, ការចូលទៅកាន់ទីផ្សារ និងមានឱកាសទទួលបានសេវាកម្មអាជីវកម្មផ្សេងៗ។

ដើម្បីសម្រេចបានការងារនេះដោយជោគជ័យ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវសិក្សា និងគិតគូរលើចំណុចមួយចំនួន ដូចខាងក្រោម៖

- បង្កើតកម្មវិធីផ្ដល់ពានរង្វាន់ដល់សហគ្រាស គ្រឹះស្ថានដែលអនុលោមតាមច្បាប់បានល្អបំផុតប្រចាំឆ្នាំ ដោយមានការប្រគល់រង្វាន់ក្នុងសប្ដាហ៍គាំពារសង្គមកម្ពុជា។
- ពិនិត្យលទ្ធភាពក្នុងការគិតគូរអំពីអន្តរាគមន៍គាំពារសង្គមនានា នៅពេលមានគ្រោះអាសន្ន។
- ផ្ដល់ឱកាសដល់សហគ្រាសធុនមីក្រូ និងធុនតូចទទួលបានប្រាក់កម្ចីក្នុងកម្រិតអត្រាការប្រាក់ទាបពីគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលរួមមាន ធនាគារសហគ្រាសធុនតូច និងមធ្យម (SME) ជាដើម។

- ផ្តល់ឱកាសដល់សហគ្រាសធុនមីក្រូ និងធុនតូចទទួលបានការបណ្តុះបណ្តាលបន្ថែមលើជំនាញផ្សេងៗពីកម្មវិធីជាតិដែលក្នុងនោះរួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ (ឧទាហរណ៍៖ ជំនាញរៀបចំរបាយការណ៍រដ្ឋបាល និងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុ)។

## ៤.៣. ការជំរុញការអនុលោមតាមបទប្បញ្ញត្តិ

វិធានការនេះ មានគោលបំណងពង្រឹងការអនុវត្តបទប្បញ្ញត្តិឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការជំរុញឱ្យសហគ្រាស គ្រឹះស្ថាន មកចុះបញ្ជីក្នុងប្រព័ន្ធ **ប.ស.ស.**។ សហគ្រាស គ្រឹះស្ថានទាំងឡាយដែលមិនបានអនុវត្តតាមបទប្បញ្ញត្តិជាធរមាន អាចប្រឈមនឹងការផាកពិន័យនានា អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការជំរុញការអនុវត្តបទប្បញ្ញត្តិឱ្យកាន់តែមានប្រសិទ្ធភាព ទាមទារនូវក្របខណ្ឌគតិយុត្ត និងបទប្បញ្ញត្តិចាំបាច់សម្រាប់គ្រប់គ្រង និងកំណត់ស្តង់ដារប្រតិបត្តិ ជាពិសេសយន្តការសហការ និងការកំណត់ច្បាស់លាស់នូវតួនាទីភារកិច្ចរបស់ភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះ, ការពង្រឹងប្រព័ន្ធអធិការកិច្ច, ការពង្រឹងសមត្ថភាពអធិការការងារ និងអធិការសន្តិសុខសង្គម, និងការដាក់ចេញនូវគោលការណ៍ណែនាំថ្មីបន្ថែមសម្រាប់ការពង្រឹងលក្ខខណ្ឌការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ជាធាតុដែលមិនអាចខ្វះបាន ក្នុងការជំរុញការចុះបញ្ជីកម្មករនិយោជិត ទៅក្នុងប្រព័ន្ធសន្តិសុខសង្គម។

ដើម្បីសម្រេចបានការងារនេះដោយជោគជ័យ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវសិក្សា និងគិតគូរលើចំណុចមួយចំនួន ដូចខាងក្រោម៖

- ពង្រឹងសមត្ថភាព និងជំនាញរបស់អធិការការងារ និងអធិការសន្តិសុខសង្គម ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពនៃបទប្បញ្ញត្តិ។
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសមត្ថកិច្ច និងការបំពេញមុខងាររបស់អធិការសន្តិសុខសង្គម ដើម្បីឱ្យអង្គភាពនេះមានសិទ្ធិអំណាចពេញលេញក្នុងការដាក់កំហិត ឬចាត់វិធានការបន្ទាន់ដល់និយោជកក្នុងសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធ ឬដល់កម្មករនិយោជិតដែលមិនអនុវត្តបទប្បញ្ញត្តិជាធរមាន។
- ពង្រឹងកិច្ចសហការ និងការចែករំលែកព័ត៌មានរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសរវាងអធិការការងារ និងអធិការសន្តិសុខសង្គម ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីស្វែងរក និងកំណត់អត្តសញ្ញាណក្រុមគោលដៅ ដែលមានទីតាំងនៅតាមក្រុង ស្រុក/ខណ្ឌនីមួយៗ។
- ពង្រឹងយន្តការផ្ទៀងផ្ទាត់ព័ត៌មានសហគ្រាស គ្រឹះស្ថាន ដែលបានចែករំលែកតាមថ្នាល CamDX និងមុនពេលវត្តមានថ្នាល CamDX ដើម្បីបង្កភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់ទិន្នន័យ និងអនុវត្តវិធានការជំរុញអនុលោមភាពនៃបទប្បញ្ញត្តិ។

## ៤.៤. ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន

វិធានការនេះ មានគោលបំណងបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍ សិទ្ធិ និងកាតព្វកិច្ច និងនីតិវិធីនៃការចុះឈ្មោះក្នុងប្រព័ន្ធសន្តិសុខសង្គមទៅដល់សាធារណជន ជាពិសេសទៅដល់ក្រុមគោលដៅដែលបានកំណត់ខាងលើ តាមរយៈការបង្កើតយន្តការស្ដីពីទំនាក់ទំនង ការអប់រំ យុទ្ធនាការផ្សព្វផ្សាយ និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។

ដើម្បីសម្រេចបានការងារនេះដោយជោគជ័យ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវសិក្សា និងគិតគូរលើចំណុចមួយចំនួន ដូចខាងក្រោម ៖

- ពង្រឹងកិច្ចសហការក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល, វិស័យឯកជន, អង្គការជាតិ និងអន្តរជាតិ និងសមាគមនានា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍ សិទ្ធិ និងកាតព្វកិច្ច និងនីតិវិធីនៃការចុះឈ្មោះក្នុងប្រព័ន្ធសន្តិសុខសង្គម។
- រៀបចំវេទិកាផ្សព្វផ្សាយ និងការប្រកួតប្រជែងចំណេះដឹងប្រចាំឆ្នាំ អំពីប្រព័ន្ធសន្តិសុខសង្គម និងគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម។
- រៀបចំវេទិកាពិភាក្សាប្រចាំខែ ដើម្បីផ្សព្វផ្សាយអំពីប្រព័ន្ធសន្តិសុខសង្គម ដោយមានការចូលរួមពីភាគីពាក់ព័ន្ធដែលរួមមានវិស័យសាធារណៈ និងឯកជន តំណាងនិយោជក និងកម្មករនិយោជិត។
- ពង្រឹងសមត្ថភាពមន្ត្រី ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយតាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមានការបណ្ដុះបណ្ដាលរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការពង្រីកការផ្សព្វផ្សាយជាសាធារណៈ នៅតាមគ្រឹះស្ថានសិក្សា និងតាមរយៈការបញ្ចូលមាតិកាពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គមទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សា។

## ៥.ក្របខណ្ឌពេល និងស្ថាប័នសម្របសម្រួល និងអនុវត្ត

ផែនការប្រតិបត្តិនេះ នឹងត្រូវបានដាក់ឱ្យអនុវត្តសម្រាប់រយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ ២០២៦ ដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាតួអង្គសម្របសម្រួល និងគាំទ្រការអនុវត្តផែនការនេះ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកការងារដូចបានកំណត់នៅក្នុងផែនការសកម្មភាព ព្រមទាំងស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការអនុវត្តផែនការនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងជោគជ័យ។ **ប.ស.ស.** នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រតិបត្តិករគោល សម្រាប់អនុវត្តផែនការប្រតិបត្តិនេះ ដោយមានកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត រួមមាន៖ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងពាណិជ្ជកម្ម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ), ក្រសួងមហាផ្ទៃ, ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "**តេជោ**", ធនាគារសហគ្រាសធុនតូច និងមធ្យម ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ ដោយឡែក, ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដែលនឹងចូលរួមគាំទ្រការអនុវត្តផែនការប្រតិបត្តិនេះ រួមមានអង្គការ ILO, UNDP, អង្គការអុកស្វាមប្រចាំកម្ពុជា ព្រមទាំងអង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធដទៃទៀត។

## ៦.យន្តការតាមដាន និងវាយតម្លៃ

យន្តការនេះ មានគោលបំណងពិនិត្យ តាមដានសកម្មភាពដែលបានដាក់ចេញ និងវាយតម្លៃសមិទ្ធផល ក៏ដូចជាកំណត់បញ្ហាប្រឈមសំខាន់ៗ សម្រាប់ជាមូលដ្ឋានក្នុងការកែសម្រួល និងការដាក់ចេញនូវវិធានការនវានុវត្តន៍ជាបន្តបន្ទាប់ ដើម្បីឱ្យការអនុវត្តផែនការនេះកាន់តែមានប្រសិទ្ធភាព សក្តិសិទ្ធិភាព និងជវភាព។ ការអនុវត្តយន្តការតាមដាន និងវាយតម្លៃនេះ នឹងត្រូវសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលផ្តោតលើចំណុចសារវន្ត ដូចខាងក្រោម៖

- តាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញ
- ពិនិត្យឡើងវិញជាប្រចាំនូវវឌ្ឍនភាព ដែលក្នុងនោះ រួមមានការកំណត់ភាពខ្លាំង ភាពខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពនៃការអនុវត្តផែនការប្រតិបត្តិដោយផ្អែកលើទិន្នន័យស្ថិតិ និងសូចនាករជាក់លាក់
- ផ្តល់កិច្ចសម្របសម្រួល និងអន្តរាគមន៍ទៅដល់ក្រសួង-ស្ថាប័នអនុវត្តក្នុងករណីចាំបាច់ ដើម្បីឱ្យការអនុវត្តផែនការមានភាពរលូន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីជ្រាបជារបាយការណ៍ និងផ្តល់ការណែនាំជាយថាហេតុ

វិធីសាស្ត្រគុណវិស័យ និងបរិមាណវិស័យ នឹងត្រូវប្រើប្រាស់ទូលំទូលាយក្នុងការប្រមូល សិក្សា និងវិភាគទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅលើការអនុវត្តគោលនយោបាយ និងលទ្ធផលដែលសម្រេចបាន។ លទ្ធផលនៃការតាមដាន និងវាយតម្លៃ ជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយ និងជាចំណេះដឹង សម្រាប់ផ្សព្វផ្សាយជាព័ត៌មានសាធារណៈ។

## ៧. សេចក្តីសន្និដ្ឋាន

ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការប្រតិបត្តិស្តីពីយន្តការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ឆ្នាំ២០២៤-២០២៦ ជាឧបករណ៍ដែលរួមចំណែកគាំទ្ររាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពង្រីកការគ្របដណ្តប់កិច្ចគាំពារផ្នែកសន្តិសុខសង្គម សំដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនប្រកបដោយសមធម៌ និងបរិយាបន្ន។ ផែនការប្រតិបត្តិនេះ ជាកាតាលីករជំរុញ និងគាំទ្រដល់សហគ្រាស គ្រឹះស្ថានឱ្យចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម ដើម្បីឱ្យនិយោជក កម្មករនិយោជិត ក៏ដូចជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម និងអន្តរាគមន៍ដទៃទៀត ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ក៏ដូចជាគោលនយោបាយពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

**ប.ស.ស.** នឹងកើនសមាជិកថ្មីដែលជានិយោជក កម្មករនិយោជិត និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះឈ្មោះក្នុងថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធយ៉ាងហោចណាស់ ១,២ លាននាក់ តាមរយៈការអនុវត្តផែនការប្រតិបត្តិនេះ ក្នុងរយៈពេល ២ឆ្នាំ។ បន្ថែមលើយន្តការសម្របសម្រួលរឹងមាំ, ឆន្ទៈក្នុងការអនុវត្ត និងកិច្ចសហការខ្ពស់ពីភាគីពាក់ព័ន្ធគឺជាសហថាមពលមិនអាចខ្វះបាន ដើម្បីគាំទ្រការអនុវត្តផែនការនេះ ក៏ដូចជាគោលនយោបាយពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព និងជោគជ័យ។ ទោះបីជាផែនការប្រតិបត្តិនេះ ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់រយៈពេល ២ឆ្នាំ និងផ្តោតជាចម្បងលើកម្មករនិយោជិតដែលកំពុងបម្រើការនៅក្នុងអង្គភាពសេដ្ឋកិច្ច ដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬមានលិខិតអនុញ្ញាត និងមានវិញ្ញាបនបត្របញ្ជិកា **ប.ស.ស.** និងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប៉ុន្តែវិធានការដែលបានកំណត់នៅក្នុងឯកសារនេះ នឹងអាចត្រូវបន្តអនុវត្តនៅឆ្នាំបន្ទាប់ ឬមានការកែសម្រួលបន្ថែម ផ្អែកតាមលទ្ធផលនៃការវាយតម្លៃជាក់ស្តែង ឬតាមការចាំបាច់ ហើយវិធានការទាំងនេះ ក៏ជួយសម្រួលដល់ដំណើរការនៃការពង្រីកវិសាលភាពរបបសន្តិសុខសង្គមទៅដល់ក្រុមគោលដៅដទៃទៀត ផងដែរ។

# ឧបសម្ព័ន្ធ ១ ៖ តារាងផែនការសកម្មភាព

| ល.រ | វិធានការគន្លឹះ | សូចនាករ | ក្របខណ្ឌពេល | ក្រសួង-ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|
| ១. ការសម្រួលយន្តការ និងនីតិវិធីនៃការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម | | | | |
| ១.១ | ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធចុះបញ្ជីតាមអនឡាញ ដោយកាត់បន្ថយឯកសារតម្រូវ និងនីតិវិធីមិនចាំបាច់ ដើម្បីសម្រួលដល់កិច្ចដំណើរការ និងនីតិវិធីចុះឈ្មោះក្នុងប្រព័ន្ធសន្តិសុខសង្គម | ប្រព័ន្ធចុះបញ្ជីត្រូវបានធ្វើបច្ចុប្បន្នកម្ម | ២០២៤-២០២៥ | ប.ស.ស. |
| ១.២ | បង្កើនទីតាំងចុះឈ្មោះតាមរយៈការចុះបញ្ជិកាឱ្យងាយស្រួលជាងមុន ដោយធ្វើការចុះឈ្មោះចល័ត, ចុះឈ្មោះដល់ទីតាំង រួមមាន ផ្សារទំនើប និងចុះផ្ទាល់តាមក្រសួង-ស្ថាប័ន, សម្រួលនីតិវិធីប្រមូលខ្ទៅដៃ និងមកយកបណ្ណ **ប.ស.ស.** ដល់ទីតាំង | យន្តការក្នុងការជំរុញការចុះបញ្ជីសមាជិក ប.ស.ស. | ២០២៤-២០២៥ | ប.ស.ស. |
| ១.៣ | សិក្សាសមិទ្ធិលទ្ធភាពនៃការអនុវត្តភាគទាន ជាកញ្ចប់គ្រួសារ ដើម្បីកៀរគរអ្នកក្នុងបន្ទុករបស់សមាជិក **ប.ស.ស.** ជាបុគ្គលស្វ័យនិយោជន៍ និងក្រុមគោលដៅដែលមានចំណូលមធ្យមអាចមានលទ្ធភាពចូលក្នុងរបបនេះ | យន្តការក្នុងការជំរុញការចុះបញ្ជីសមាជិក ប.ស.ស. | ២០២៥ | ប.ស.ស. |
| ១.៤ | សិក្សាលទ្ធភាពដាក់ឱ្យអនុវត្តយន្តការចែករំលែកទិន្នន័យ និងព័ត៌មានចាំបាច់នៃចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធមុនវត្តមានប្រព័ន្ធថ្នាល CamDX ដាក់ឱ្យដំណើរការ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ | យន្តការចែករំលែកទិន្នន័យ | ២០២៥-២០២៦ | -**ដឹកនាំ** ៖ ក.ស.ហ.វ.<br>-**គាំទ្រ**៖ ក.ក.ប., អ.ក.គ, ប.ស.ស, ក.ព.ណ., ក.ឌ.វ.ប.ន., ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ១.៥ | សិក្សាលទ្ធភាពដាក់បញ្ចូលមុខរបរអាទិភាពវូបនីយកម្មផ្នែកក្រៅប្រព័ន្ធជាដំណាក់កាលៗទៅតាមស្ថានភាពជាក់ស្តែងដើម្បីផ្តល់អត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម | លទ្ធផលនៃការសិក្សាមុខរបរអាទិភាពវូបនីយកម្មផ្នែកក្រៅប្រព័ន្ធត្រូវបានកំណត់ | ២០២៥-២០២៦ | -**ដឹកនាំ**៖ ក.ឌ.វ.ប.ន. (គ.ស.អ.ស.ក)<br>-**គាំទ្រ**៖ ប.ស.ស., អ.ក.គ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| **២. ការផ្តល់ការលើកទឹកចិត្ត** | | | | |
| ២.១ | រៀបចំកម្មវិធីផ្តល់ពានរង្វាន់ដល់សហគ្រាស គ្រឹះស្ថានដែលអនុលោមតាមច្បាប់បានល្អបំផុតប្រចាំឆ្នាំ | កម្មវិធីផ្តល់ពានរង្វាន់ត្រូវបានរៀបចំ | ២០២៥-២០២៦ | ប.ស.ស. |
| ២.២ | រៀបចំយន្តការកំណត់ប្រភេទ កម្រិត ឬទំហំអត្ថប្រយោជន៍បន្ថែម ឬការលើកទឹកចិត្តទៅដល់ក្រុមគោលដៅ ដូចជា៖<br>- សិក្សាលទ្ធភាពកំណត់កម្រិតអត្រាការប្រាក់កម្ចីពីធនាគារ SME<br>- លទ្ធភាពក្នុងការគិតគូរអំពីអន្តរាគមន៍គាំពារសង្គមនានានៅពេលមានគ្រោះអាសន្ន<br>- ពិនិត្យលទ្ធភាពការផ្តល់ការលើកទឹកចិត្តផ្សេងៗទៀត<br>- រៀបចំយន្តការលើកទឹកចិត្ត និងផ្តល់សមាជិកភាព ប.ស.ស. ដល់អ្នកប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធលើគ្រប់វិស័យ និងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាពទាំង១៥ | យន្តការនៃការផ្តល់ការលើកទឹកចិត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ២០២៤-២០២៥ | -**ដឹកនាំ ៖** ប.ស.ស.<br>-**គាំទ្រ៖** អ.ក.គ, ធនាគារ SME, ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| **៣. ការជំរុញការអនុលោមតាមបទប្បញ្ញត្តិ** | | | | |
| ៣.១ | រៀបចំយន្តការសហការរវាងអធិការការងារ, អធិការសន្តិសុខសង្គម, អាជ្ញាធរមូលដ្ឋាន, និងស្ថាប័នពាក់ព័ន្ធក្នុងការស្វែងរក និងកំណត់អត្តសញ្ញាណក្រុមគោលដៅ ដើម្បីជំរុញការអនុវត្តវិធានការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម | យន្តការសហការរវាងភាគីពាក់ព័ន្ធដើម្បីជំរុញការចុះបញ្ជីត្រូវបានរៀបចំ និងអនុវត្ត | ២០២៤-២០២៥ | -**ដឹកនាំ៖** ក.ក.ប.<br>-**គាំទ្រ៖** ប.ស.ស., ក.ឱ.វ.ប.ន., ក.ព.ណ, ក្រសួងមហាផ្ទៃ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួង-ស្ថាប័នពាក់ព័ន្ធ |

| ៤. លើកកម្ពស់ការយល់ដឹងរបស់សាធារណជន | | | | |
|---|---|---|---|---|
| ៤.១ | រៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាព និងផ្សព្វផ្សាយផ្ទាល់នៅតាមទីតាំងសហគ្រាស គ្រឹះស្ថាន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ការផ្សព្វផ្សាយនៅតាមទីតាំងសហគ្រាស គ្រឹះស្ថាន ត្រូវបានរៀបចំ | ២០២៥ | -**ដឹកនាំ៖** ប.ស.ស.<br>-**គាំទ្រ៖** ក.ខ.វ.ប.ន. (គ.ស.អ.ស.ក), អ.ក.គ., ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤.២ | រៀបចំវេទិកាពិភាក្សា ឬកម្មវិធីប្រកួតប្រជែងចំណេះដឹងប្រចាំខែ និងប្រចាំឆ្នាំ អំពីប្រព័ន្ធសន្តិសុខសង្គម និងគោលនយោបាយបាយពាក់ព័ន្ធ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដូចជាតំណាងវិស័យសាធារណៈ, តំណាងនិយោជក, តំណាងកម្មករនិយោជិត និងតំណាងសិស្ស-និស្សិត ជាដើម | វេទិកាពិភាក្សា ឬកម្មវិធីប្រកួតប្រជែងចំណេះដឹង ត្រូវបានរៀបចំ | ២០២៤-២០២៥ | -**ដឹកនាំ៖** ប.ស.ស.<br>-**គាំទ្រ៖** ក.ខ.វ.ប.ន. (គ.ស.អ.ស.ក), អ.ក.គ., ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤.៣ | រៀបចំការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយតាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីត្រូវបានរៀបចំ | ២០២៤-២០២៥ | -**ដឹកនាំ៖** ប.ស.ស.<br>-**គាំទ្រ៖** ក.ខ.វ.ប.ន. (គ.ស.អ.ស.ក), អ.ក.គ., ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤.៤ | រៀបចំកម្មវិធីចែករំលែកព័ត៌មានប្រចាំសប្តាហ៍ ឬប្រចាំខែអំពីនីតិវិធី និងដំណើរការចុះបញ្ជីក្នុងប្រព័ន្ធសន្តិសុខសង្គម សិទ្ធិនិងកាតព្វកិច្ចនៃការចុះបញ្ជី និងអត្ថប្រយោជន៍ពីប្រព័ន្ធសន្តិសុខសង្គម ទៅដល់សាធារណជន | កម្មវិធីចែករំលែកព័ត៌មាន ត្រូវបានរៀបចំ | ២០២៤-២០២៥ | -**ដឹកនាំ៖** ប.ស.ស.<br>-**គាំទ្រ៖** ក.ខ.វ.ប.ន. (គ.ស.អ.ស.ក), អ.ក.គ., ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤.៥ | ពង្រីកការផ្សព្វផ្សាយជាសាធារណៈ នៅតាមគ្រឹះស្ថានសិក្សា និងតាមរយៈការបញ្ចូលមាតិកាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សា | ការផ្សព្វផ្សាយនៅតាមគ្រឹះស្ថានសិក្សាត្រូវបានរៀបចំ | ២០២៤-២០២៦ | -**ដឹកនាំ៖** ប.ស.ស.<br>-**គាំទ្រ៖** អ.ក.គ, ក្រសួងអប់រំ យុវជន និងកីឡា, ក.ខ.វ.ប.ន. (គ.ស.អ.ស.ក), ក្រសួង-ស្ថាប័នពាក់ព័ន្ធ |

## ឧបសម្ព័ន្ធ ២ ៖ និយមន័យ

- **កម្មករនិយោជិត** សំដៅដល់ជនគ្រប់ភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃ ក្រោមការដឹកនាំ និង គ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬ នីតិបុគ្គលជាសាធារណៈ ឬឯកជន។
- **សហគ្រាសធុនមីក្រូ** សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំក្រោម ៦២ ២៥០ ដុល្លារអាមេរិក ឬមានចំនួនកម្មករនិយោជិតក្រោម ៥នាក់។
- **បុគ្គលស្វ័យនិយោជន៍** សំដៅដល់ជនប្រកបការងារ ឬមុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួលឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជក ឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានការប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារ ឬមុខរបររបស់ខ្លួន។
- **កម្មករនិយោជិតម្តងម្កាល** សំដៅដល់ជនដែលចុះកិច្ចសន្យាធ្វើការមួយជាប្រាកដ តាមធម្មតាត្រូវតែឱ្យហើយក្នុងរយៈពេលយ៉ាងខ្លី និងធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើមួយរដូវៗ។
- **ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (Cambodia Data Exchange – CamDX) សំដៅដល់ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានាដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ក្នុងគោលដៅភ្ជាប់ជាប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល។
- **ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន** (Online Business Registration System–OBR) សំដៅដល់ថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចុះបញ្ជីអាជីវកម្ម និងស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រជំនាញ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើកដំបូងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងកត់ត្រានូវចំណុចចាប់ផ្តើមនៃការដ្ឋានកែទម្រង់មួយរបស់រាជរដ្ឋាភិបាល។

**សម្គាល់៖**

- យោងតាមអង្កេតកម្លាំងពលកម្ម ២០១៩, **វិស័យក្រៅប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសដែលមិនបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និងគ្មានបញ្ជីគណនេយ្យពេញលេញ។ វិស័យក្រៅប្រព័ន្ធមិនរាប់បញ្ចូលគ្រួសារដែលផលិតសម្រាប់តែការប្រើប្រាស់ចុងក្រោយខ្លួនឯង, កសិកម្មសម្រាប់ចិញ្ចឹមជីវិត និងការសាងសង់លំនៅឋានខ្លួនឯង។ល។ **ការងារក្រៅប្រព័ន្ធ** រួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការងារក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិត និងអ្នករៀនធ្វើការ និងអ្នកហាត់ការដែលគ្មានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមបង់ភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

NATIONAL SOCIAL PROTECTION COUNCIL